ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆមាសទី១ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ តាមការកត់សម្គាល់ឃើញថាការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេស សម្រេចបានចំនួន ១ ២៨៣ ៩៦២ហ.ត ស្មើនឹង៤៩,៦៥% នៃផែនការ ២ ៥៨៦ ១៥២ហ.ត។ ការប្រើប្រាស់គ្រឿងយន្ត សម្រាប់ការរៀបចំដីផលិតកម្មដំណាំស្រូវរដូវវស្សាគឺស្មើនឹង៩៩,០៨% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន០,៩២% រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្ម ទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆមាសទី១ ឆ្នាំ២០១៩នេះគឺ បានរៀបចំសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការចូលរួមរៀបចំពិធីច្រត់ព្រះនង្គ័ល ការរៀបចំកិច្ចប្រជុំសំខាន់ៗ ការទទួលជួបភ្ញៀវជាតិ-អន្តរជាតិ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆមាសទី១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៩

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាមានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ១ ៥៤៨ ៧៣៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៤ ២៧១ហ.ត និងដោយគ្រឿងយន្តមានចំនួន ១ ៥៣៤ ៤៦៣ហ.ត តិចជាងឆ្នាំមុនចំនួន ២៣៧ ២២៥ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៦ ៥៤៩ ហ.ត តិចជាងឆ្នាំមុនចំនួន ១២ ៨៩៩ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ១ ២៨៣ ៩៦២ហ.ត ស្មើនឹង៤៩,៦៥% នៃផែនការ ២ ៥៨៦ ១៥២ហ.ត តិចជាងឆ្នាំមុនចំនួន ២១០ ៧៣៣ហ.ត។

#### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សាឆ្នាំ២០១៩

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៣១ ១១៩ហ.ត ស្មើនឹង៥៩,៨៦% នៃផែនការ ៥១ ៤៩២ហ.ត តិចជាងឆ្នាំមុនចំនួន ៣ ៧២៤ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៥៦៨ ៩៥០ហ.ត ស្មើនឹង៦៧,៨៤% នៃផែនការ ៨៣៨ ២២០ហ.ត តិចជាងឆ្នាំមុនចំនួន ១២៥ ៦០៩ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០

### ១.៣ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករក្នុងឆមាសទី១ ឆ្នាំ២០១៩ បានចំនួន ២៨១ ៥៣៨តោន ការនាំចេញទៅកាន់ទិសដៅចំនួន ៤៧ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ (១១៨ ៤០១តោន) ប្រទេសបារាំងលំដាប់ទី២ (៣៧ ៥១៥តោន) ប្រទេសហ្កាបុងលំដាប់ទី៣ (១៦ ៩១៩តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ (១៣ ៩៣៦តោន) ប្រទេសប្រ៊ុយណេលំដាប់ទី៥ (១២ ១៨០តោន) ប្រទេសណេដឺឡែនលំដាប់ទី៦ (៩ ២១៩តោន) ប្រទេសអូស្ត្រាលីលំដាប់ទី៧ (៨ ០៣៥តោន) ប្រទេសវៀតណាមលំដាប់ទី៨ (៧ ៨៥៥តោន) ប្រទេសអេស្ប៉ាញលំដាប់ទី៩ (៧ ៥២៣តោន) និងប្រទេសប៊ែលហ្ស៊ិកលំដាប់ទី១០ (៦ ០៧៦តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៧៥ក្រុមហ៊ុន។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តប្រចាំឆមាសទី១ (តោន) | បញ្ចេញលក់ប្រចាំឆមាសទី១ (តោន) |
|---|---|---|---|---|---|
| I.ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៦៧០ | ៨០១ | ២០៨ | ១៥០ |
| **សរុប I** | | **៦៧០** | **៨០១** | **២០៥** | **១៥០** |
| II. ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុនសុភក្តិនិកា អ៊ីនវេសមេនគ្រុប | ១២ ៨៨៧ | ១៥ ៧៥៧ | ៦ ៤៩៥ | ៦ ៧២៤ |
| ២ | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | ១ ២២៦ | ១ ៩២៨ | ៦៤៥ | ៦៧២ |
| ៣ | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៥ ៦៣១ | ៨ ៤៤០ | ១ ៦៣៣ | ១ ៨៩២ |
| ៤ | ក្រុមហ៊ុន ស៊ីហ្វរ៉ាប់ប៊ើលីមីធីត (រតនគិរី) | ៧៩ | ២ ៧២៤ | ៩៩ | ២១ |
| ៥ | ក្រុមហ៊ុនស៊ីហ្វវីសសស៍(ស្នួល) | ៣ ៨៥៩ | ៤ ៤០៦ | ១ ៤១០ | ១ ៤១៧ |
| ៦ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ៩០៨ | ៤ ១៨៧ | ៨៩៩ | ១ ៣០២ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៤១៨ | ៤ ៨៣៣ | ៧២៦ | ៨២៣ |
| ៨ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ២ ០១០ | ៣ ៣២២ | ៤៣២ | ៥៣០ |
| ៩ | ក្រុមហ៊ុនក្រែក(ខេមបូឌា)ខូអិលធីឌី | ៤ ៣៥៩ | ៤ ៧៩៨ | ២ ៤៨៨ | ២ ៧៣០ |
| **សរុបII** | | **៣៧ ៣៧៧** | **៥០ ៣៩៥** | **១៤ ៨២៧** | **១៦ ១១១** |
| III. ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧០ ១០០ | ២២១ ៧១៤ | ៣៦ ៨០០ | ៣៥ ៣០០ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ១២៥ ០៦៥ | ១៦១ ១០៣ | ៥៣ ៧០០ | ៥២ ៧០០ |
| **សរុប III** | | **១៩៥ ១៦៥** | **៣៨២ ៨១៧** | **៩០ ៥០០** | **៨៨ ០០០** |
| **សរុប I + II + III** | | **២៣៣ ២១២** | **៤៣៤ ០១៣** | **១០៥ ៥៣២** | **១០៤ ២៦១** |

គួរកត់សម្គាល់ថាជ័រកៅស៊ូក្នុងខែមិថុនា ឆ្នាំ២០១៩នេះមានតម្លៃជាមធ្យម ១ ៤០០ដុល្លារ/តោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមរៀបចំផែនការស្រាវជ្រាវទាក់ទងទៅនឹងបច្ចេកទេសប្រមូលផលកៅស៊ូជាមួយជំនាញការបារាំង CIRAD
- លាយថ្នាំរំញោច Ethephon ដើម្បីលាបលើបច្ច័យពិសោធន៍តាមពិធីពិសោធន៍
- ស្រង់ទិន្នន័យទឹកជ័រលើចម្ការពិសោធន៍ទាំង១៣ក្នុងនិងក្រៅស្ថានីយ
- ត្រួតពិនិត្យតាមដានការលាបថ្នាំរំញោច Ethephon នៅតាមគ្រប់បណ្តាចម្ការពិសោធន៍
- បានដាក់ជីនៅច្បារបង្កាត់ពូជ និង SET02
- ថែទាំកូនកៅស៊ូស៊ីដលីង ច្បារបង្កាត់ពូជ SET02 និង SSCT02
- ពិភាក្សាការងារជាមួយជំនាញការ CIRAD ពីការរៀបចំពិសោធន៍ និងទិសដៅស្រាវជ្រាវបង្កាត់ពូជ

- ចុះវាស់ទំហំដើម និងកម្រាស់សំបកតាមដើមនីមួយៗនៅឡូតិ៍ MKAA01 នៅខេត្តមណ្ឌលគិរី
- ជំរឿនដើមកូនកៅស៊ូងាប់ដាំឆ្នាំ២០១៩
- រៀបចំបោះបង្គោលតំរុយ និងខួងរណ្ដៅសម្រាប់ដាំកូនកៅស៊ូឆ្នាំ២០១៩
- កាប់រណ្ដៅ និងដាំជួសនៅឡូតិ៍៥២CS និងឡូតិ៍៤២BNW ដាំឆ្នាំ២០១៨
- រក្សាទុកកូនកៅស៊ូចំនួន ១កូនប្លុកសម្រាប់ការបំបៅ Clone Exchange និងក្លូនពីចិន
- ខួងរណ្ដៅឡូតិ៍៤២BNE សម្រាប់ដាំជុះឆ្នាំ២០១៩
- បានធ្វើតេស្តប្រៀបធៀបក្នុងស្រុកលើកទី៥៧ ជាមួយក្រុមហ៊ុនចំនួន៤។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ក្នុងការរៀបចំវេទិកាផ្គូផ្គងអ្នកធ្វើអាជីវកម្មកែច្នៃផលិតផលកសិកម្ម ចំណីអាហារ និងធុរកិច្ចជនទាំងក្នុងនិងក្រៅប្រទេស

- បានចូលរួមប្រជុំពិគ្រោះយោបល់ស្ដីពីការតាក់តែងប្រតិបត្តិស្តង់ដារសម្រាប់មន្ទីរពិសោធន៍ផលិតផលកសិកម្ម និងចំណីអាហារ

- បានចូលរួមសិក្ខាសាលាស្តីពីការអនុវត្តកិច្ចព្រមព្រៀងកសិកម្ម (AoA) និងកិច្ចព្រមព្រៀង (SPS) ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងជំរុញការនាំចេញផលិតផលកសិកម្ម

- បានរៀបចំ និងពិនិត្យឡើងវិញនូវវិធីសាស្ត្រសម្រាប់វិភាគរកសមាសធាតុ អាស៊ូត (N) ផូស្វ័រ (P) និងប៉ូតាស្យូម (K) នៅក្នុងផលិតផលកសិកម្ម និងចំណីអាហារ

- បានវិភាគរកសមាសធាតុ អាស៊ូត (N) ផូស្វ័រ (P) នៅក្នុងជីកំប៉ុស្ត

- ពិសោធន៍សាកល្បងលើការផ្សំអាហារបំប៉នសម្រាប់បណ្តុះមេផ្សិតម្ចូល

- បានចុះបើកវេទិកាប្រជុំចរចាការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងភាគីអ្នកផលិត និងអ្នកទិញនៅខេត្តព្រៃវែង

- បានចុះបើកវេទិកាប្រជុំផ្សព្វផ្សាយស្តីពីការជំរុញការនាំចេញផលិតផលកសិកម្មតាមកិច្ចសន្យាជាមួយក្រុមហ៊ុនរោងចក្រ សហគ្រាស នៅខេត្តកំពង់ចាម

- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តតាកែវ

- បានចុះបណ្តុះបណ្តាលកសិករស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម

- បានធ្វើការអប់រំផ្សព្វផ្សាយចំនួន ២លើកស្តីពីការការពារការពុលមេតាណុល និងសារធាតុគីមីផ្សេងទៀតក្នុងផលិតផលស្រាស

- បានចូលរួមប្រជុំពិភាក្សាលើសេចក្តីព្រាងគោលនៃផែនការសម្រាប់អភិវឌ្ឍន៍ស្វាយចន្ទីកម្ពុជាជាមួយជំនាញការ Top Planning។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- បានចុះពិនិត្យផ្ទៀងផ្ទាត់គម្របព្រៃឈើឆ្នាំ២០១៨ នៅទីវាលជាក់ស្តែងចំនួន ២៧៧ចំណុច នៅខេត្តក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុន និងអតិថិជនចំនួន៧ និងអ្នកស្នើសុំចំនួន ៣នាក់ ដែលមានឈើហ៊ុបមូលចំនួន ២៨ ៩៩៣ម³ ឈើអារចំនួន ៨៤៣ម³ ឈើប្រណិតចំនួន ១០៨ម³ ឈើជ្រុងចំនួន ២ ៧៩០ម³ កូនឈើចំនួន ១២៤ ០៩២ដើម អុសចម្រុះចំនួន ៣៨ ៧២៦ស្ទែរ ជន្លង់ម្រេចចំនួន ៤០៣ដើម សសរចំនួន ១១ដើម ធ្យូងចំនួន ១០ ៨៨០គ.ក្រ និងគល់បេងចំនួន ៤០៩គ.ក្រ និងជ័រទឹកចំនួន ១៩២តោន។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- បានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ៥លើក នៅខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង កំពង់ធំ និងខេត្តព្រះវិហារ ដោយរឹបអូសបានសាច់ជ្រូកព្រៃចំនួន ៤៩គ.ក្រ សាច់ឈ្លូសចំនួន ១២គ.ក្រ សត្វអន្សងរស់ចំនួន ២ក្បាល សត្វក្រកួតរស់ចំនួន ២ក្បាល រណារយន្តចំនួន ២គ្រឿង និងប្រទះឃើញជ្រូកព្រៃជាប់អន្ទាក់ងាប់ចំនួន ១ក្បាល

- បានប្រមូលសំណាករុក្ខជាតិគេសរកុល (អ័រគីដេព្រៃ) ចំនួន ៤លើក បានចំនួន ៤៧០សំណាកត្រូវជា៣៦ប្រភេទ នៅខេត្តស្ទឹងត្រែង មណ្ឌលគិរី កោះកុង និងខេត្តព្រះវិហារ ក្រៅពីនោះបានប្រមូលសំណាករុក្ខជាតិប្រភេទ Hoya

Nepenthes Drosera និងប្រភេទ Moss យកទៅសិក្សាស្រាវជ្រាវ និងថែរក្សាតាមដានបន្តពីដំណុះពូជរុក្ខជាតិនៅសួនអររីដេភ្នំពេញថ្មី។

**៤.៣ បង្កាត់ពូជសត្វក្នុងការណ៍ និងការសង្គ្រោះសត្វព្រៃ**

- ក្រុមហ៊ុនចំនួន ៦មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញចំនួន ៧ទីតាំងនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានសត្វស្វាក្ដាមសរុបចំនួន ៥៤ ៣៦៥ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៧ ៤៦៩ក្បាល

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៩ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៥៧៥ក្បាល (បក្សី ៥៣ប្រភេទ ថនិកសត្វ ៤១ប្រភេទ និងល្មូន ១៣ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៣៦០ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ១៣២ក្បាល ស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៣៥២ក្បាល។

**៤.៤ ការងារដាំដើមឈើ**

- បានអនុវត្តការងារបណ្ដុះកូនឈើចំនួន ១០១ ៥០០ដើម សម្រាប់ដាំជាចម្ការថ្មីនៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ និងស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអូរថ្ម ខេត្តព្រះសីហនុ

- បណ្ដុះកូនឈើគ្រប់ប្រភេទចំនួន ៥២២ ៨៥២ដើម និងប្រគេនចែកចាយកូនឈើដល់ព្រះសង្ឃ ប្រជាពលរដ្ឋចំនួន ៥៣ ៥៣៤ដើម នៅក្នុងថ្នាលបណ្ដុះកូនឈើតាមបណ្ដាខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្ត និង ថ្នាលបណ្ដុះកូនឈើចំនួន ៦កន្លែង ក្នុងខេត្តកណ្ដាល ពោធិ៍សាត់ កំពង់ធំ តាកែវ និងខេត្តកំពង់ចាម។

**៤.៥ ការងារនីតិកម្មនិងវិវាទ**

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៩នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៤១៦ករណី ដោយពិន័យអន្តរការណ៍ចំនួន ២២៧ករណី និងបញ្ជូនទៅតុលាការចំនួន ១៨៩ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន ឈើមូល-ជ្រុងចំនួន ១៣៨ម៣ ឈើអារចំនួន ១ ០១៨ម៣ គ្រាក់ក្រញូងចំនួន ២ម៣ សត្វព្រៃចម្រុះប្រភេទចំនួន ១ ៧៨៩ក្បាល និង២៣០គ.ក្រ និងអនុផលព្រៃឈើព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត។ សំណុំរឿងកាប់រានដីព្រៃចំនួន ២៩ករណី ស្មើនឹង ១ ២៤៦ហ.ត ត្រូវបានបញ្ជូនទៅតុលាការ

- ចុះពង្រឹងការអនុវត្តច្បាប់ចំនួន ៤០លើក ក្នុងខេត្តចំនួន ១៦មានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ តាកែវ សៀមរាប ឧត្តរមានជ័យ កំពង់ធំ ព្រះវិហារ ប៉ៃលិន បន្ទាយមានជ័យ កោះកុង ព្រៃវែង ស្វាយរៀង រតនគិរី កំពត និងខេត្តក្រចេះ។

**៤.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

- បានចុះពិនិត្យដល់ទីតាំងជាក់ស្ដែងតាមលក្ខណៈបច្ចេកទេសជូនក្រុមហ៊ុនចំនួន២០ដែលបានស្នើសុំបន្តសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើចំនួន១៤កន្លែង និងស្នើសុំបង្កើតចំនួន៦កន្លែង

- ក្រុមហ៊ុនចំនួន៦ធ្វើការនាំចេញផលិតផលគ្រឿងសង្ហារិម និងរានទេវតាទៅក្រៅប្រទេសមានបរិមាណសរុបចំនួន ១ ២៧៣ម៣ និងជ័រទឹកចំនួន១០០តោន។ ក្រុមហ៊ុនចំនួន៣ធ្វើការនាំចូលឈើអារកែច្នៃ (MDF Wood Panel និង CHAN-FUTA) មានបរិមាណឈើចំនួន១ ០០៩ម៣

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន៩មានបរិមាណផលិតផលឈើកែច្នៃចំនួន១ ១០៧ម៣ ផលិតផលកែច្នៃចំនួន១១៦តោន ព្រមទាំងផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន៣ មានបរិមាណឈើកែច្នៃចំនួន ១ ១៩៦ម៣។

**៤.៧ ការងារចំណូលព្រៃឈើ**

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៩នេះ ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើសរុបចំនួន ២០ ៣២៨ ៥២៣ ៩៦៨ រៀល និង១០៣ ១២៧,៦៣ដុល្លារ។

## ៥ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៥.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្ដុះបណ្ដាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដារាជធានី-ខេត្តរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយ

អំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ។

### ៥.២ ការងារបសុពេទ្យ

• **លទ្ធផលត្រួតពិនិត្យ បង្ក្រាបបទល្មើសសត្វ និងផលិតផលមានដើមកំណើតពីសត្វ៖** ក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ រាជធានី-ខេត្តចំនួន២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៧០ ៥៣៥លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តសរុបចំនួន ២១១ករណី ក្នុងនោះឃាត់ចាប់ចំនួន ៣១ករណី និងត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន ១៨០ករណី។

• **ការងារសុខភាពសាធារណៈ៖** ចុះបង្កើនការយល់ដឹងការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈបច្ចេកទេសចំនួន ១៥ខេត្ត ចុះវាយតម្លៃទីតាំងស្នើសុំសាងសង់សត្តឃាតដ្ឋាននៅខេត្តស្ទឹងត្រែង។ បច្ចុប្បន្នសត្តឃាតដ្ឋានស្របច្បាប់សរុបចំនួន ២០០កន្លែង។

• **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ជំងឺឆ្លងសត្វ និងធ្វើការផ្សព្វផ្សាយជំងឺប៉េស្តជ្រូកអាហ្វ្រិកនៅខេត្តចំនួន ១៩រួមមាន ខេត្តក្រចេះ រតនគិរី កែប កំពត កំពង់ស្ពឺ តាកែវ មណ្ឌលគិរី ស្ទឹងត្រែង បន្ទាយមានជ័យ បាត់ដំបង សៀមរាប កំពង់ធំ ប៉ៃលិន កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង និងខេត្តស្វាយរៀង។

• **ការងារនីតិកម្មនិងវិវាទ៖**

- ព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិតលាយផ្សំ ការវេចខ្ចប់ជាថ្មី ការសន្និធិ ការផ្គត់ផ្គង់ ចែកចាយ ការលក់ដុំ និងលក់រាយបសុឱសថ។

### ៥.៣ ការងារស្រាវជ្រាវ

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០០ក្បាល ក្នុងនោះគោប្រាម៉ាន់កាត់ ២៨ក្បាល កូនគោបៅដោះ ៣៥ក្បាល គោកំផែងសែន ៣៧ក្បាល។ ដោយឡែក នៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ២៤៣ក្បាល។

• **ការងារស្រាវជ្រាវបសុពេទ្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៦ ៩៥២វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) មានផ្ទុះ១ករណីនៅភូមិសោមកានិញ ឃុំសោមធំ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី និងនៅភូមិកំពង់សេរី និងភូមិសោយ ឃុំមាន ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- ដាយត្រីបានបញ្ចប់ត្រឹមចំនួន ២ ៣៧០តោន ស្មើនឹង១៩,៧៥% នៃផែនការ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ថយចុះចំនួន ២២០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៣៣ ៥០០តោន ស្មើនឹង៣៨,៧០% នៃផែនការ ៣៤៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៥២០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៣២ ០៨០តោន ស្មើនឹង២២,១២% នៃផែនការ ១៤៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៨០តោន។

#### ៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៥៧ ៨០០តោន ស្មើនឹង៥២,៥៥% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៣៥០តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ១១២ ៨៤៦តោន ស្មើនឹង៣៧,៦២% នៃផែនការ ៣០០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ១៨ ៨០៨តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ១៤១ ៤០០ក្បាល ស្មើនឹង៤៧,១៣% នៃផែនការ ៣០០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ១០ ៩០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៨៣ ០០០ ០០០កូន ស្មើនឹង៣៤,៥៨% នៃផែនការ ២៤០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួនប្រមាណ ៤ ០០០ ០០០កូន។

**៦.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ២៧ ៨៥០តោន ស្មើនឹង៣៣,៩៦% នៃផែនការ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ១៧០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៦ ០២០តោន ស្មើនឹង៦៦,៨៩% នៃផែនការ ៩ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៨០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៣៦ ៦០០ ០០០លីត្រ ស្មើនឹង៦៦,៥៥% នៃផែនការ ៥៥ ០០០ ០០០ លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ១ ០០០ ០០០លីត្រ។

**៦.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល**

- សម្រាប់ឆមាសទី១ ឆ្នាំ២០១៩នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ១ ៣២១ករណី ប្រៀបធៀបក្នុងឆ្នាំ២០១៨ ថយចុះចំនួន ១២៦ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ២០២ករណី និងសមុទ្រចំនួន ១១៩ករណី។

**៦.៥ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់អនុវត្តបានចំនួន ៥ ៤៦០តោន ស្មើនឹង៣៦,៤០% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៨០តោន

- ផលនេសាទកែច្នៃអនុវត្តបានចំនួន ៣ ២៥០តោន ស្មើនឹង៦៥% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ កើនឡើងចំនួន ៣០តោន។

**៦.៦ ការប្រមូលថវិកា**

ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលក្នុងឆមាសទី១ ឆ្នាំ២០១៩ ចំនួន ៣៧៥ ៣៧៨ ៨៧២រៀល ស្មើនឹង១២,៣៤% នៃផែនការ ៣ ០៤៣ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ថយចុះចំនួន ២៤៥ ០៧៤ ៩៩១រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចុះប្រមូលសំណាកផ្កាអ័រគីដេ និងដំណាំផ្សេងទៀតចំនួន ៣០សំណាក បន្តការអភិរក្សពូជដំណាំចំនួន ៣៨ ប្រភេទរួមមានស្រូវចំនួន ៦ ៧៣១បញ្ជីក/សំណាក ដំណាំផ្សេងៗចំនួន ៣៧ប្រភេទ សរុបចំនួន ៨ ៨២៧បញ្ជីក/សំណាក។ ដាំវាយតម្លៃ និងកំណត់លក្ខណៈសំណាកត្រសក់ស្រូវ ម្ទេស និងល្ពៅ បានចំនួន ៥៣,៥៨ និង២៤សំណាករៀងគ្នា។ កំពុងរៀបចំចងក្រងសៀវភៅ (Catalogue) ពីរច្បាប់សម្រាប់ពូជម្ទេស និងត្រសក់ស្រូវ

- បានធ្វើពិសោធន៍ចំនួន ៥៦ប្រភេទ នៅ៤៨៦កន្លែងដែលក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ២៨៥កន្លែង។ ធ្វើទិវាស្រែចំនួន ៤លើកមានកសិករចូលរួមចំនួន ២៣១នាក់ និងបើកវគ្គបណ្តុះបណ្តាលចំនួន ១វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ២៦នាក់

- បានត្រៀមរៀបចំឯកសារដាក់ជូនគណៈកម្មការបញ្ចេញប្រភេទពូជដំណាំពិនិត្យ ដើម្បីបញ្ចេញពូជដំណាំចំនួនបីពូជ (ស្រូវ ល្ង និងសណ្តែកសៀង)

- បានបោះពុម្ពឯកសារចំនួន ១៧ ០២០ច្បាប់ និងបែងចែកឯកសារសរុបចំនួន ៧ ៧៥០ច្បាប់។ ចំនួនអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់វិទ្យាស្ថានតាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួនសរុប ៤៥០ ១៣៣នាក់

- បានចែកគ្រាប់ពូជសុទ្ធគ្រឹះសរុបចំនួន ៤៧៥គ.ក្រ នៃពូជស្រូវផ្កាមាលតីដែលក្រសួងទើបបញ្ចេញជូនកសិករកាលពីឆ្នាំមុនជូនដល់អគ្គនាយកដ្ឋានកសិកម្មចំនួន ១០០គ.ក្រ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

## ៨ ផ្នែកនីតិកម្មកសិកម្ម

**៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម**

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ១១៥ក្រុមហ៊ុន សរុបចំនួន ១ ៣៦៩មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១១៤ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចេញជីកសិកម្មចំនួន ១ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣០ក្រុមហ៊ុន

- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣៩ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៥៣ក្រុមហ៊ុន សរុបចំនួន ៣៩២សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពីបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្មនៅខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងខេត្តព្រៃវែង។

### ៨.៤ ការងារអនុវត្តច្បាប់

- ធ្វើការពិន័យអន្តរការណ៍ចំពោះក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មពុំបានប្រកាសប្រតិវេទន៍ស្តីពីការនាំចូលសម្ភារកសិកម្មចំនួន ៧ក្រុមហ៊ុន។

## ៩ ផ្នែករដ្ឋបាល

- ក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ បានទទួលលិខិតសរុបចំនួន ៤ ៨១៩ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានា ចំនួន ២ ១២៦ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១ ៨៧៤ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៨១៩ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល
- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៦ ៣៩៩ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរណែនាំចំនួន ២៧៥ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១០៦ច្បាប់
- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានរៀបចំសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វេទិកាកសិកម្ម និង ចូលរួមរៀបចំព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំ២០១៩។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៦៦ ៧១នាក់ (ស្រី១ ៦០១នាក់) ស្មើនឹង២៣,៩៩% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៨៦៧នាក់ (ស្រី៨៣៥នាក់) ស្មើនឹង២៩,១២%
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ៣ ៨០៤នាក់ (ស្រី៧៦៦នាក់) ស្មើនឹង២០,១៣%
- បានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៣០២នាក់ (ស្រី៨៧នាក់)
- បានចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន ១៩នាក់ (ស្រី៤នាក់) ក្នុងនោះ បោះបង់ចោលការងារចំនួន៣នាក់ សុំលាឈប់ការងារចំនួន៧នាក់ និងមរណភាពចំនួន៩នាក់
- បានចេញប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន៦នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន៩នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន៧នាក់
- បានចេញប្រកាសដាក់ឲ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំនួន៧រូប
- បានចេញប្រកាសអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារវិញបន្ទាប់ពីស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំនួន២នាក់
- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៦៧នាក់ (ស្រី៣៥នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៣៨នាក់ (ស្រី១២នាក់) ច្បាប់រយៈពេលខ្លីចំនួន ២នាក់ (ស្រី១នាក់) ច្បាប់ពិសេសចំនួន២នាក់ (ស្រី១នាក់) ច្បាប់ឈប់សម្រាកព្យាបាលជំងឺចំនួន៤នាក់ និងច្បាប់សម្រាកមាតុភាពចំនួន ២១នាក់

- បានរៀបចំធ្វើលិខិតស្នើសុំគ្រឿងឥស្សរិយយសជូនក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន ៩នាក់ ទៅទីស្ដីការគណៈរដ្ឋមន្ត្រី

- បានរៀបចំធ្វើលិខិតស្នើសុំផ្ដល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន៤រូប

- ការងារបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេសសរុបចំនួន ៦១០នាក់ (ស្រី១១៣នាក់) ក្នុងនោះៈ

  + ការបណ្ដុះបណ្ដាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ៣៧៧នាក់ (ស្រី៥៩នាក់)

  + ការបណ្ដុះបណ្ដាលក្រៅប្រទេសសរុបចំនួន ២៣៣នាក់ (ស្រី៥៤នាក់)។

## ១១ មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បន្តសកម្មភាពការងារលើការតាមដាន និងថែទាំគេហទំព័ររបស់ក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តឲ្យដំណើរការរលូនជាប្រចាំ

- សម្អាត Catch នៅលើ Cloud server នៃគេហទំព័រទាំង៤១

- រៀបចំកម្មវិធីទូរស័ព្ទឆ្លាតវៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Mobile App) កំពុងបញ្ចូលព័ត៌មានដើម្បីប្រកាសដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ២០១៩ ខាងមុខដែលបានបញ្ចូលកម្មវិធីសម្រាប់ប្រើលើទូរស័ព្ទទៅក្នុង Play Stores (Android) និង App Stores (iOS)

- បន្តសកម្មភាពការងារលើការធ្វើបច្ចុប្បន្នភាពគេហទំព័រ និងចុះបណ្ដុះបណ្ដាល តាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១១ដូចជា ខេត្តប៉ៃលិន ឧត្តរមានជ័យ កំពង់ឆ្នាំង បាត់ដំបង ព្រះវិហារ ពោធិ៍សាត់ បន្ទាយមានជ័យ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង និងខេត្តស្វាយរៀង

- បានរៀបចំវគ្គបណ្ដុះបណ្ដាលចំនួន ១វគ្គ ស្ដីពីបច្ចេកវិទ្យាព័ត៌មានផ្សារភ្ជាប់នឹងវិស័យកសិកម្ម

- សកម្មភាពការងារក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រកសិកម្មបានរៀបចំកាត់ផែនទីតាមរាជធានី-ខេត្តចំនួន ១០ដូចជា ខេត្តបន្ទាយមានជ័យ ស្វាយរៀង កណ្ដាល មណ្ឌលគិរី រតនគិរី កែប កំពង់ស្ពឺ ព្រះសីហនុ ក្រចេះ និងខេត្តស្ទឹងត្រែង និងបានប្រមូលទិន្នន័យគ្រោះមហន្តរាយដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ កែសម្រួលផ្ទាំងលោតលើគេហទំព័រដើម្បីបង្ហាញព័ត៌មានទិន្នន័យកសិកម្មលើដំណាំច្រើនប្រភេទ ព្រមទាំងបានចុះបណ្ដុះបណ្ដាលការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រកសិកម្ម និងប្រមូលចងក្រងទិន្នន័យគ្រោះមហន្តរាយ ដល់មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៤ដូចជា ខេត្តឧត្តរមានជ័យ ស្វាយរៀង មណ្ឌលគិរី និងខេត្តក្រចេះ។

## ១២ ផ្នែកសវនកម្មផ្ទៃក្នុង

- ធ្វើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២

- ធ្វើសេចក្ដីសម្រេចស្ដីពីការបង្កើតក្រុមការងារទាមទារប្រាក់ពីមន្ត្រីរាជការដែលបោះបង់ចោលការងារ

- បានចុះធ្វើសវនកម្មចំនួន ២៦សវនដ្ឋាន ស្មើនឹង៥៣,០៦% នៃផែនការ៤៩សវនដ្ឋាន និងផ្ដល់អនុសាសន៍កែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ១៧៨អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥០,៣៧% នៃផែនការចំនួន៥០%។

## ១៣ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលលើការចុះហត្ថលេខាបន្តសុពលភាពលើអនុស្សរណៈយោគយល់គ្នារវាងអាស៊ាន-ចិន លើវិស័យអនាម័យ និងភូតគាមអនាម័យ

- បានធ្វើលិខិតទៅទីស្ដីការគណៈរដ្ឋមន្ត្រី ករណីសុំការអនុញ្ញាតដាក់សំណើសុំចូលជាសមាជិកនៃអង្គការបណ្ដាញអន្តរជាតិសម្រាប់ឬស្សី និងផ្ដៅ ក្នុងរបៀបវារៈប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីស្នើសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ

- បានសម្របសម្រួលលិខិតជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈប្រតិភូចូលរួមទស្សនកិច្ចនៅវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (IRRI) ប្រទេសហ្វីលីពីន

- សុំគាំទ្រហិរញ្ញវត្ថុដើម្បីបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្មរវាងកម្ពុជា-ម៉ូរីស

- សុំការអនុញ្ញាតនាំចេញដើមរុក្ខជាតិមួយចំនួនដើម្បីទៅចូលរួម និងរៀបចំពិព័រណ៍សាកវប្បកម្មអន្តរជាតិឆ្នាំ២០១៩ នៅទីក្រុងប៉េកាំង ប្រទេសចិន

- បានធ្វើលិខិតសុំការឯកភាពលើការអនុវត្តអនុស្សរណៈយោគយល់គ្នារវាងកម្ពុជា-តួកគី ស្ដីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម

- សម្របសម្រួលករណីសុំគោរពអញ្ជើញឯកឧត្តមរដ្ឋមន្ត្រីដើម្បីចូលរួមទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្មឆ្នាំ២០១៩ និងខួបលើកទី២៥នៃ UNCCD នៅទីក្រុង Ankara ប្រទេសតួកគី

- បានសម្របសម្រួល និងរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការអនុវត្តកិច្ចព្រមព្រៀងកសិកម្ម (AoA) និងកិច្ចព្រមព្រៀង SPS ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងការជំរុញការនាំចេញផលិតផលកសិកម្មនៅខេត្តកំពត។

## ១៤ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង
- ចុះពិនិត្យនិងតាមដានវាយតម្លៃវត្ថុតាងបទល្មើសផល អនុផលព្រៃឈើសម្រាប់ដាក់ដេញថ្លៃ ឬពិគ្រោះថ្លៃ
- ចុះពិនិត្យនិងវាយតម្លៃជាក់ស្តែងសម្រាប់គណនាថ្លៃសម្បទានដីសេដ្ឋកិច្ចត្រូវបង់ចូលថវិការដ្ឋរបស់ក្រុមហ៊ុន
- បានរៀបចំលិខិតអន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីសំណើសុំគោលការណ៍ផានាចំណាយឥណទានថវិកាជំពូក២១ សម្រាប់គាំទ្រដំណើរការគម្រោងកម្មវិធីជំរុញផលិតកម្មស្បៀងរយៈពេល១២ខែ
- ចូលរួមពិនិត្យផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះប្រចាំឆ្នាំ២០១៨ និងជំរុញការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

## ១៥ ផ្នែកអគ្គាធិការដ្ឋាន

- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង
- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ ការគ្រប់គ្រង និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនត្រូវកែលម្អរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ កំពង់ឆ្នាំង កណ្តាល ព្រៃវែង ស្វាយរៀង ឧត្តរមានជ័យ និងខេត្តតាកែវ
- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលជលផលសៀមរាប ពិនិត្យស្ថានភាពនៃការធ្វើវារីវប្បកម្មក្រពើ និងតម្លៃកូនក្រពើនៅខេត្តសៀមរាប។

## ១៦ ផ្នែកផែនការនិងស្ថិតិ

- អនុញ្ញាតជាគោលការណ៍ផ្តល់ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាលនូវស្រូវពូជចំនួន ២០ ៧៣៤គ.ក្រ
- ចុះប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធការដាំដុះដំណាំ និងចិញ្ចឹមសត្វក្នុងគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចនៅខេត្តក្រចេះ កំពង់ចាម កំពង់ធំ កំពង់ស្ពឺ កំពត ត្បូងឃ្មុំ សៀមរាប រតនគិរី មណ្ឌលគិរី ព្រះវិហារ ស្ទឹងត្រែង កោះកុង និងខេត្តព្រះសីហនុ
- បានចុះណែនាំស្ទង់ទិន្នផលស្រូវរដូវប្រាំងឆ្នាំ២០១៨-២០១៩
- បានចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំធ្វើអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩
- ធ្វើការតាមដានការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សា ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សា ២០១៩
- ចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលទូទាំង២៥ រាជធានី-ខេត្ត
- រៀបចំសិក្ខាសាលាស្តីពីទស្សនទានទីផ្សារកសិកម្មឆ្នាំ២០១៩ នៅខេត្តកំពង់ចាមមានអ្នកចូលរួមសរុបចំនួន ៦៣នាក់
- ចុះពិនិត្យតាមដានអំពីការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មនៅខេត្តក្រចេះ ស្ទឹងត្រែង កំពង់ចាម ត្បូងឃ្មុំ កំពង់ស្ពឺ កោះកុង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង កែប ព្រះសីហនុ សៀមរាប បន្ទាយមានជ័យ តាកែវ កំពត ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង ប៉ៃលិន ព្រះវិហារ ឧត្តរមានជ័យ កំពង់ធំ និងខេត្តកណ្តាល
- បានចុះពិនិត្យលទ្ធផលការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៨ និងផ្សព្វផ្សាយទិសដៅសម្រាប់ការអនុវត្តឆ្នាំ២០១៩ តាមបណ្តាខេត្តចំនួន ៨រួមមាន៖ ខេត្តកំពង់ធំ បាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ចាម ត្បូងឃ្មុំ ព្រះវិហារ និងខេត្តក្រចេះ
- ចុះរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់បរិស្ថានដល់កសិករចំនួន៣វគ្គនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ។

## ១៧ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៧.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៨-២០១៩ សរុបចំនួន ៣ ០៥២នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- ចុះធ្វើកម្មសិក្សានៅខេត្តសៀមរាប និស្សិតបានសិក្សាអំពីស្ថានភាពនៃការចិញ្ចឹមសត្វ ជំងឺសត្វ ការបង្រៀនអំពីជំងឺផ្តែផ្តួតដល់កសិករចំនួន ២២២នាក់ និងសិស្សានុសិស្សសាលាបឋមសិក្សាចំនួន ១៩៣នាក់ ចាក់ថ្នាំការពារជំងឺផ្តែផ្តួតដល់ផ្តែឆ្មាចំនួន ១៦៨ក្បាល ការពារជំងឺ ៥មុខ(DHPPL)ចំនួន ១២៥ក្បាល ទំលាក់បរាសិត ១៩៥ក្បាល និងក្រៀវនិងព្យាបាលផ្តែបានមួយចំនួន ចាក់ថ្នាំទំលាក់បរាសិតគោក្របីចំនួន ១០៧ក្បាល និងចាក់វីតាមីនដល់គោក្របីចំនួន ៥៨ក្បាល យកសំណាកឈាម ៣១សំណាក និងសំណាកលាមក ៦២សំណាកសម្រាប់សិក្សាពិសោធន៍ស្រាវជ្រាវ

- ចូលរួមទិវាពិភពលោកដើម្បីប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម ឆ្នាំ២០១៩ និងខួបលើកទី២៥ របស់ UNCCD ក្រោមប្រធានបទ សូមរីកចម្រើនទាំងអស់គ្នានាពេលអនាគតនៅខេត្តកំពត

- បានចូលរួមធ្វើបទបង្ហាញ ចែករំលែកចំណេះដឹង ក្នុងសិក្ខាសាលាពិគ្រោះយោបល់ លើចំណុចអាទិភាព ភាពស៊ាំឱសថអង់ប៊ីយ៉ូទិកក្នុងសុខភាពសត្វ

- បានចុះអនុស្សរណៈយោគយល់ជាមួយក្រុមហ៊ុន Climate smart technology ដើម្បីធ្វើការពង្រឹងការប្រើប្រាស់បច្ចេកវិទ្យា ICT សម្រាប់ការរៀន ការបង្រៀន និងការគ្រប់គ្រងការងារសិក្សា

- បានទទួលជួបពិភាក្សាជាមួយថ្នាក់ដឹកនាំក្រុមហ៊ុន Industrial Technology Centre EHIME Prefecture ប្រទេសជប៉ុន ដើម្បីស្វែងយល់ពីកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវលើការកែច្នៃផលិតផលកសិកម្ម

- បានទទួលជួបពិភាក្សាជាមួយគណៈប្រតិភូ CIRAD ប្រទេសបារាំងស្តីពីការបង្កើតកិច្ចសហការគ្នា លើការស្រាវជ្រាវ និងបណ្តុះបណ្តាលកៅស៊ូនៅកម្ពុជា។

### ១៧.២ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ សរុបចំនួន ៩៨៣នាក់ (ស្រី៤១៩នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បាននិងកំពុងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធជាមួយគោ ត្រី ចេក បន្លែ និងរុក្ខជាតិ។ ការអប់រំ និងការស្រាវជ្រាវមានកិច្ចសហប្រតិបត្តិការជាមួយដៃគូផ្សេងៗមកពីក្នុង និងក្រៅប្រទេសមានចិន កូរ៉េ វៀតណាម និងថៃ

- ពិសោធន៍គោសាច់ចំនួន ១៦ក្បាល ចិញ្ចឹមត្រី និងកំពឹសនៅក្នុងអាងស៊ីម៉ងត៍

- បន្តសហការជាមួយ Vitrosyste ក្រុមហ៊ុនប្រទេសកូរ៉េ ជំរុញស្រាវជ្រាវផ្នែកបណ្តុះជាលិកា

- ជំរុញការស្រាវលើដំណាំចេកអំបូងពណ៌លឿងរបស់ជប៉ុនក្នុងផ្ទះសំណាញ់

- បន្តសហការជាមួយក្រុមហ៊ុនចិន ពិសោធន៍លើការចិញ្ចឹមត្រីនាគ បបែលនិងត្រី Symphysodon។

### ១៧.៣ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៨-២០១៩ សរុបមានចំនួន ៦៥៩នាក់ (ស្រី២៩៦នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានសហការជាមួយអង្គការ ERICON ធ្វើការអប់រំកសិករស្តីពីកសិកម្មសរីរាង្គនៅតាមបណ្តាស្រុកព្រៃឈរ ស្រុកស្ទឹងត្រង់ ស្រុកកងមាស និងស្រុកកំពង់ចាម

- បានរៀបចំពិសោធន៍ជីសរីរាង្គលើការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- បានរៀបចំសាកល្បងផលិតមេជី *Lacto bacillus* និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម

- ពិសោធន៍ប្រៀបធៀបការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម

- បន្តការងារមន្ទីរពិសោធន៍ចិញ្ចឹម និងភ្ញាស់ដង្កូវនាងព្រៃ។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេសសម្រេចបានចំនួន ១ ២៨៣ ៩៦២ហ.ត ស្មើនឹង៤៩,៦៥% នៃផែនការ ២ ៥៨៦ ១៥២ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេស មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការ

ត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ក្រសួងបានសហការជាមួយស្ថាប័នពាក់ព័ន្ធមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្មក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអន្តរស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៨-២០១៩ ជាពិសេសនៅតំបន់ភូមិ-សាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- រៀបចំឱ្យមានកិច្ចប្រជុំការងារគ្រឿងយន្តកសិកម្មជាមួយក្រុមហ៊ុនឯកជន និងផ្នែកពាក់ព័ន្ធនានា
- ត្រៀមរៀបចំបង្កើតផែនទីវិភាគអំពីសហគមន៍កសិកម្មទូទាំងប្រទេស
- បន្តរៀបចំផែនការការងារដើម្បីធ្វើចម្ការបង្ហាញលើការគ្រប់គ្រងជីជាតិដីតំបន់ខ្ពង់រាប នៅខេត្តកោះកុង កំពង់ចាម មណ្ឌលគិរី និងខេត្តរតនគិរី សរុបចំនួន ១០ទីតាំង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាននិងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល និងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅអនុវត្តបន្ត
- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះថ្លៃកសិផល និងទីផ្សារកសិផលជាយថាហេតុ
- យកចិត្តទុកដាក់គិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឲ្យប៉ះពាល់សុខុមាលភាពសាធារណៈ ការនាំចេញកសិផលទៅក្រៅប្រទេស និងលើកកម្ពស់ផលិតកម្មកសិកម្មសរីរាង្គ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ និងធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

## ២ ផ្នែកផលិតកម្មនិងបសុពេទ្យាបាល

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តតាមដានស្ថានភាពជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជាប្រចាំនៅតាមរាជធានី-ខេត្ត

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពី នីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល នាំចេញ ឆ្លងកាត់ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិ ផ្គត់ផ្គង់ចែកចាយ លក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ

- បន្តរៀបចំសេចក្តីព្រាងស្តីពីវិធាន នីតិវិធីចុះបញ្ជីចំណីសត្វ និងបសុឱសថ ព្រមទាំងកិច្ចការសម្រួលពាណិជ្ជកម្មដល់វិស័យឯកជន

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមរាជធានី-ខេត្ត

- ចុះធ្វើអង្កេត តាមដាន ស្រាវជ្រាវ យកវត្ថុវិភាគ និងស្រង់ព័ត៌មានជំងឺឆ្លងសត្វ។

## ៣ ផ្នែកព្រៃឈើ

- ចុះពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបកស្រាយគម្របព្រៃឈើឆ្នាំ២០១៨ ធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងព្រៃសហគមន៍ សហការជាមួយអង្គការដៃគូដើម្បីពង្រឹងការរៀបចំ និងអនុវត្តកម្មវិធីសហគមន៍ព្រៃឈើ

- បង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានលើប្រព័ន្ធបច្ចេកទេសប្រព័ន្ធភូមិសាស្ត្រ (GIS) និងប្រព័ន្ធកំណត់ទីតាំងលើផែនដី (GPS)

- បន្តសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធដើម្បីចុះស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរសត្វព្រៃ និងបន្តប្រមូលព័ត៌មាន ជំរុញការចុះបញ្ជិកានៃការចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារ សួនសត្វ និងកសិដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត

- បន្តសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាដើម្បីសិក្សាស្រាវជ្រាវ ថែរក្សា និងអភិរក្សសត្វព្រៃ ជីវចម្រុះ និងចុះផ្សព្វផ្សាយការទប់ស្កាត់ការជួញដូរសត្វព្រៃ សារសំខាន់សត្វព្រៃ និងច្បាប់ស្តីពីព្រៃឈើ

- បន្តចុះតាមដានត្រួតពិនិត្យផ្ទៀងផ្ទាត់លើការងារពាក់ព័ន្ធការកាប់រានដីព្រៃឈើ ចូលរួមសហការការងារជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងផ្ទៀងផ្ទាត់សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ កាប់រានដីព្រៃ និងវត្ថុតាងនៃបទល្មើសព្រៃឈើ

- បន្តជំរុញការងារបណ្តុះកូនឈើសម្រាប់ ចែកចាយដល់កសិករដាំអាស្រ័យផល និងចុះសិក្សាទីតាំងដីសម្រាប់បង្កើតជាស្ថានីយ និងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ

- បន្តការងារស្រាវជ្រាវក្រពើភ្នំ និងបង្រៀនប្រជាសហគមន៍ពីបច្ចេកទេសកសិកម្ម និងការចិញ្ចឹមសត្វ

- បន្តលើកផែនការយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ និងការប្រើប្រាស់ផល អនុផលព្រៃឈើប្រចាំឆ្នាំ និង៥ឆ្នាំ

- សម្របសម្រួល និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូអភិវឌ្ឍន៍ និងអាស៊ាន និងអង្គការពាណិជ្ជកម្ម

ពិភពលោកតាមដានការអនុវត្តកិច្ចព្រមព្រៀងអនុស្សរណៈ អនុសញ្ញាជាតិដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជាលេខ០១ និង០២ របស់រាជរដ្ឋាភិបាល និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

## ៤ ផ្នែកជលផល

- បន្តការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអនុសាសន៍៧ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៩ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរស់ ត្រីឆ្លោឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តសកម្មភាពការងារបង្កើតទម្រង់បន្ថែមលើប្រព័ន្ធគេហទំព័រភូមិសាស្ត្រកសិកម្ម និងរៀបចំទម្រង់នៃការបញ្ចូលទិន្នន័យព័ត៌មាន ទីតាំងប្រមូលទិញ ទីតាំងលក់ រោងម៉ាស៊ីនកិនស្រូវ ដែលតម្រូវឱ្យ Admin Page បញ្ចូលព័ត៌មានសំខាន់ៗ

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា បន្តផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

នៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្ដុះបណ្ដាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការរៀបចំច្បាប់ផ្សេងៗ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទតាមការចាំបាច់ និងលំដាប់អាទិភាព

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា ហើយក៏ជាយន្តការមួយរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ពីកសិកម្មបែបវិបុលវប្បកម្មដែលមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលអាកាសធាតុ ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម៕

ថ្ងៃ អង្គារ ១៥កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**